ព្រឹត្តិបត្រព័ត៌មាន សមាគមស្វាយចន្ទីកម្ពុជា
CAC's Quarterly Report

+855 77 629 288/+855 31 5555 706 info@cac-camcashew.org https://cac-camcashew.org/

កញ្ញា ២០២៦ - ឆ្នាំទី ៣ លេខ ១១
September 2026 – Volume 3 Issue 11





អាស័យដ្ឋាន / Address:

ផ្លូវជាតិលេខ ៦, សង្កាត់អាចារ្យលាក់, ក្រុងស្ទឹងសែន, ខេត្តកំពង់ធំ
National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom

សារពីប្រធានសមាគម - Message from the President



Silot Uon
President, Cashew Nut Association of Cambodia

គោរពជូន សមាជិក ដៃគូ និងភាគីពាក់ព័ន្ធទាំងអស់,

កម្ពុជាកំពុងលេចធ្លោឡើងជាប្រទេសផលិតគ្រាប់ស្វាយចន្ទីធំមួយ ប៉ុន្តែទិន្នផលផលិតកម្មតែមួយមុខមិនអាចកំណត់អនាគតនៃឧស្សាហកម្មនេះបានឡើយ។ បញ្ហាប្រឈមកាន់តែធំ គឺការធានាថាតម្លៃបន្ថែមដែលបានមកពីគ្រាប់ស្វាយចន្ទីកម្ពុជាត្រូវតែរក្សាទុកនៅក្នុងប្រទេសឱ្យបានកាន់តែច្រើន។

សមាគមស្វាយចន្ទីកម្ពុជា (សសក) បានបោះជំហានក្នុងការឈ្វេងយល់ និងសហការជាអន្តរជាតិជាមួយបណ្តាប្រទេសផលិតគ្រាប់ធំៗ រួមមាន ហ្គាណា នីហ្សេរីយ៉ា និងកូតឌីវ័រ ព្រមទាំងមានផែនការសិក្សាពីវិស័យស្វាយចន្ទីរបស់ប្រទេសតង់សានីផងដែរ។ បទពិសោធន៍ទាំងនេះអាចជួយឱ្យសសក កំណត់បាននូវវិធីសាស្ត្រជាក់ស្តែងក្នុងការកែច្នៃ ការវិនិយោគ និងការអភិវឌ្ឍខ្សែច្រវាក់ផ្គត់ផ្គង់។

តួលេខជាក់ស្តែងបានបង្ហាញពីឱកាសដ៏ធំធេងនេះ។ ទិន្នន័យក្រៅផ្លូវការ កម្ពុជាផលិតគ្រាប់ស្វាយចន្ទីឆៅបានប្រមាណ ១,០៨ លានតោន ក្នុងរយៈពេលប្រាំបីខែដំបូងនៃឆ្នាំ២០២៦ ប៉ុន្តែមានសេចក្តីរាយការណ៍ថា ត្រឹមតែប្រហែល ២% ប៉ុណ្ណោះដែលត្រូវបានកែច្នៃនៅក្នុងស្រុក។ គម្លាតនេះបង្ហាញពីកាលានុវត្តភាពដ៏សំខាន់សម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ការបង្កើតការងារ និងការធ្វើពិពិធកម្មការនាំចេញ។ ទោះជាយ៉ាងណា ការគ្រាន់តែកសាងរោងចក្រតែមួយមុខ មិនអាចដោះស្រាយបញ្ហាបានទាំងស្រុងនោះទេ។ កម្ពុជាត្រូវការបណ្តាញប្រមូលទិញគ្រាប់ស្វាយចន្ទីឆៅ ដែលអាចទុកចិត្តបាន ទុនបង្វិល វត្ថុធាតុដើមមានគុណភាព បច្ចេកវិទ្យា ជំនាញបច្ចេកទេស ឃ្លាំងស្តុក និងការតភ្ជាប់ទីផ្សារអន្តរជាតិ។

ការវិនិយោគពីបរទេសអាចផ្តល់នូវដើមទុន បច្ចេកវិទ្យា និងទំនាក់ទំនងទីផ្សារ ខណៈដែលវិនិយោគិនកម្ពុជាអាចកសាង

Dear Members, Partners, and Stakeholders,

Cambodia is emerging as a major raw cashew nut producer, but production alone will not determine the future of the industry. The greater challenge is ensuring that more of the value generated by Cambodia's cashews remains in the country.

The Cashew Nut Association of Cambodia (CAC) has wisely pursued international study and cooperation with major producing countries, including Ghana, Nigeria and Côte d'Ivoire, and plans to study Tanzania's cashew sector. These experiences can help Cambodia identify practical approaches to processing, investment and supply-chain development.

The figures highlight the opportunity. Cambodia produced about 1.08 million tonnes of raw cashew nuts during the first eight months of 2026, yet only around 2% was reportedly processed domestically. This gap represents a significant opportunity for industrial development, employment and export diversification.

However, building factories alone will not solve the problem. Cambodia needs reliable RCN procurement networks, working capital, quality raw materials, technology, technical expertise, storage and international market access.

Investment from abroad can provide capital, technology and market connections, while Cambodian investors can build stronger domestic

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ភាពជាម្ចាស់ក្នុងស្រុកកាន់តែរឹងមាំ និងរក្សាផលប្រយោជន៍សេដ្ឋកិច្ចរយៈពេលវែងឱ្យនៅគង់វង្សបានកាន់តែប្រសើរ។ វិធីសាស្ត្រទាំងពីរនេះគួរតែបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ជាជាងការផាត់ចេញពីគ្នា។

អ្វីដែលសំខាន់បំផុតនោះ កសិករត្រូវតែបន្តស្ថិតនៅចំស្នូលនៃខ្សែច្រវាក់តម្លៃ។ ឧស្សាហកម្មកែច្នៃប្រកបដោយភាពប្រកួតប្រជែង គួរតែធានាការផ្គត់ផ្គង់វត្ថុធាតុដើមដល់អ្នកកែច្នៃឱ្យបានទៀងទាត់ ស្របពេលដែលធានាថាកសិករទទួលបានតម្លៃសមរម្យ និងមានភាពប្រកួតប្រជែង។

ដូច្នេះ បញ្ហាប្រឈមជាយុទ្ធសាស្ត្របន្ទាប់សម្រាប់វិស័យស្វាយចន្ទីកម្ពុជា មិនមែនគ្រាន់តែជាការបង្កើនបរិមាណផលឱ្យបានកាន់តែច្រើននោះទេ ប៉ុន្តែគឺការស្រូបយកតម្លៃបន្ថែមឱ្យបានកាន់តែច្រើនបំផុតពីគ្រាប់ស្វាយចន្ទីគ្រប់ៗគោនដែលបានផលិត។

អ៊ួន ស៊ីឡុត, ប្រធាន សសក

ownership and retain greater long-term economic benefits. These approaches should complement rather than exclude each other.

Most importantly, farmers must remain central to the value chain. A competitive processing industry should provide processors with reliable supplies while ensuring farmers receive fair and competitive prices.

Cambodia's next cashew challenge is therefore not simply producing more, but capturing more value from every tonne produced.

Silot Uon, President of CAC







National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

បេសកកម្ម ចក្ខុវិស័យ គោលដៅ - Mission, Vision, and Goals

បេសកកម្ម - Mission

ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់អំណាចដល់កសិករស្វាយចន្ទី និងការលើកកម្ពស់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ CAC មានគោលបំណងពង្រឹងរូបភាពឧស្សាហកម្មគ្រាប់ស្វាយចន្ទីទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ ដើម្បីធានាបាននូវកំណើន និងវិបុលភាព។

To alleviate poverty by empowering cashew farmers and promoting sustainable agricultural practices, in alignment with government policy. CAC aims to strengthen the cashew nut industry's image both nationally and internationally, ensuring its growth and prosperity.

ចក្ខុវិស័យ - Vision

ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាអ្នកដឹកនាំសកលក្នុងការផលិត និងការលក់ទីផ្សារគ្រាប់ស្វាយចន្ទីដោយជំរុញការច្នៃប្រឌិត និងនិរន្តរភាព ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងរួមចំណែកដល់ការអភិវឌ្ឍន៍ជាតិ។

To position Cambodia as a global leader in cashew production and marketing, fostering innovation and sustainability to enhance the livelihoods of local communities and contribute to the national economy.

គោលដៅ - Goals

- ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសដល់កសិករស្វាយចន្ទី និងសហគមន៍កសិកម្មនៅទូទាំងប្រទេសកម្ពុជា។
- បង្កើតឃ្លាំងសហគមន៍នៅគ្រប់ខេត្តដែលផលិតស្វាយចន្ទី។
- បើកដំណើរការរោងចក្រកែច្នៃដំបូងរបស់ CAC សម្រាប់ការបណ្តុះបណ្តាលអ្នកកែច្នៃ។
- ប្រែក្លាយខេត្តកំពង់ធំឱ្យទៅជាតំបន់ឧស្សាហកម្មស្វាយចន្ទីធំជាងគេបង្អស់នៅកម្ពុជា។

- Provide technical training to cashew nut farmers and agricultural cooperatives across Cambodia.
- Establish community warehouses in all cashew-producing provinces.
- Launch CAC's first processing factory for processor training.
- Transform Kampong Thom into Cambodia's largest cashew industrial zone.

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ទិដ្ឋភាពទូទៅនៃវិស័យស្វាយចន្ទី - Cashew industry at a glance


The phenomenon of El Niño is anticipated to impact Cambodia during the months of October and November in 2026, coinciding with the cashew blooming season.

សារធ្រើនរំលឹកជាបន្ទាន់ជូនបងប្អូនកសិករស្វាយចន្ទី!

⚠️ ត្រៀមលក្ខណៈសម្រាប់ខ្លួននឹង «គ្រោះអាសន្ន អែលនីណូ (El Niño)» ក្នុងឆ្នាំ២០២៦

១. ខែសីហា & កញ្ញា ឆ្នាំ២០២៦៖ បរិមាណទឹកភ្លៀងនៅមានកម្រិតមធ្យមទៅច្រើន (តំបន់ភាគច្រើនមានពណ៌ខៀវ និង ស) ធ្វើឱ្យដីនៅមានសំណើមល្អ។

២. ខែតុលា & វិច្ឆិកា ឆ្នាំ២០២៦៖ ប្រទេសកម្ពុជានឹងជួបប្រទះ វិបត្តិរាំងស្ងួតធ្ងន់ធ្ងរ និងកើនកម្តៅខ្លាំង (បង្ហាញដោយពណ៌ក្រហម និងត្នោតចាស់ស្ទើរតែពេញផ្ទៃប្រទេស)។



គណៈកម្មការនិពន្ធនិងផ្សព្វផ្សាយ
Editorial and Publication Committee

លោក អួន ស៊ីឡុត (Mr. Silot Uon)
President of CAC, Chief Editor
silot.uon@cac-camcashew.org

លោក ស៊ុយ កុកធាន (Mr. Suy KokThean)
Head of Public Relations/International Affairs
suvkokthean@hotmail.com

លោក ម៉ា វុទ្ធី (Mr. Ma Vuthy)
Head of Admin and Finance

លោក ទ្រី គីមស្រៀង (Mr. Try Kimsreang)
Technical Assistant

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

តារាងមាតិកា - Table Of Contents

1. ព័ត៌មានសមាគម ស្វាយចន្ទី កម្ពុជា - Cashew Nut Association of Cambodia 7

.....10

2. ព័ត៌មានអន្តរជាតិ - International News..... 15

3. ព័ត៌មានក្នុងស្រុក - Local News 22

សសក ចុះអនុស្សារណៈយោគយល់ជាមួយ ធនាគារចិន នៅកម្ពុជា.....25

CAC Inked MoU with Bank of China in Phnom Penh.....25

CAC Holds First Cashew Farmer Training Workshop in Kampong Chhnang 27

Cambodian Civil Society Delegation Explores China Experience and Cashew Cooperation 30



National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

1. ព័ត៌មានសមាគម ស្វាយចន្ទី កម្ពុជា - Cashew Nut Association of Cambodia



★★★ ព័ត៌មានសំខាន់ៗ - News Highlights

SDF និង សសក បង្កើនការបណ្តុះបណ្តាលជំនាញសម្រាប់ឧស្សាហកម្មស្វាយចន្ទីកម្ពុជា

កំពង់ធំ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៦ — មូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) និងសមាគមស្វាយចន្ទីកម្ពុជា (សសក) បានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងកម្លាំងពលកម្មកែច្នៃស្វាយចន្ទីរបស់កម្ពុជា តាមរយៈការវាយតម្លៃរួមគ្នាក្នុងឧស្សាហកម្ម និងការរៀបចំកម្មវិធីបណ្តុះប-ណ្តាលឆ្លើយតបតាមតម្រូវការទីផ្សារ។

ដឹកនាំដោយ **ឯកឧត្តម គី សុខគីម** នាយកប្រតិបត្តិនៃ SDF និង **លោក អួន ស៊ីឡុត** ប្រធាន សសក ប្រតិភូបានចុះទស្សនកិច្ចនៅក្រុមហ៊ុន Pinex Agro និងក្រុមហ៊ុន MIRARTH Agri Tech ក្នុងខេត្តកំពង់ធំ ដើម្បីវាយតម្លៃប្រតិបត្តិការរោងចក្រស្វែងរកគម្លាតជំនាញបច្ចេកទេស និងពិភាក្សាអំពីតម្រូវការកម្លាំងពលកម្មជាមួយថ្នាក់ដឹកនាំឧស្សាហកម្មស្វាយចន្ទី។ គំនិតផ្តួចផ្តើមនេះធ្វើឡើងបន្ទាប់ពីមានកិច្ចព្រមព្រៀងដៃគូនា

SDF, CAC Advance Skills Training for Cambodia's Cashew Processing Industry

Kampong Thom, July 24, 2026 — The Skills Development Fund (SDF) and the Cashew Nut Association of Cambodia (CAC) have stepped up efforts to strengthen Cambodia's cashew processing workforce through a joint industry assessment and the development of demand-driven training programs.

Led by SDF CEO H.E. Ky Sokkim and CAC Chairman Silot Uon, a delegation visited Pinex Agro and MIRARTH Agri Tech in Kampong Thom to assess factory operations, identify technical skill gaps, and discuss workforce needs with industry leaders.

The initiative follows a recently signed partnership between SDF and CAC and supports the Royal Government's National Policy on Cashew Nuts to expand domestic processing and value addition.

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ពេលថ្មីៗនេះរវាង SDF និង សសក ព្រមទាំងចូលរួមគាំទ្រដល់«គោលនយោបាយជាតិស្តីពីស្វាយចន្ទី» របស់រាជរដ្ឋាភិបាល ក្នុងការពង្រីកការកែច្នៃក្នុងស្រុក និងការបង្កើតតម្លៃបន្ថែម។

បេសកកម្មនេះក៏មានការចូលរួមពីវិទ្យាស្ថានពហុ-បច្ចេកទេសខេត្តកំពង់ធំ (PIKT) ដើម្បីបញ្ចប់ផែនការសម្រាប់កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល (ToT) និងកម្មវិធីកសាងសមត្ថភាពអ្នកកែច្នៃ ដោយផ្តោតលើការអភិវឌ្ឍអ្នកបច្ចេកទេសជំនាញ អ្នកបញ្ជាគ្រឿងចក្រជាងមេកានិច និងបុគ្គលិកត្រួតពិនិត្យគុណភាព ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជានៅលើទីផ្សារស្វាយចន្ទីសកល។

The mission also brought together the Polytechnic Institute of Kampong Thom (PIKT) to finalize plans for Training of Trainers (ToT) and processor capacity-building programs, with a focus on developing skilled technicians, machine operators, mechanics, and quality-control personnel to enhance Cambodia's competitiveness in global cashew markets.

ផ្សែតណាមកើបចំណូលជិត ៥០ ពាន់លានដុល្លារ ពីការនាំចេញផលិតផលកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល ៨ ខែដើមឆ្នាំនេះ កើនឡើង ៧% បើធ្យៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ខណៈផ្លែឈើ បន្លែ និងផលិតផលនេសាទនៅតែជាក្រុមទំនិញដែលជួយជំរុញកំណើន។ នេះបើតាមការចុះផ្សាយរបស់ភ្នាក់ងារសារព័ត៌មាន VNS។ KPT Economy

សសក រួមចំណែកក្នុងកិច្ចសន្ទនាកែទម្រង់រវាងរាជរដ្ឋាភិបាល និងវិស័យឯកជន

ភ្នំពេញ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៦ — សមាគមស្វាយចន្ទីកម្ពុជា (សសក) បានចូលរួមក្នុងសិក្ខាសាលាជាន់ខ្ពស់ស្តីពីរបៀបវារៈនៃការកែទម្រង់របស់រាជរដ្ឋាភិបាល ក្រោមវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ដោយបានគូសបញ្ជាក់ពីកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់រវាងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីកែលម្អបរិយាកាសធុរកិច្ចនៅកម្ពុជា។

សិក្ខាសាលាដែលដឹកនាំដោយ ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម ស៊ុន ចាន់ថុល បានរាយការណ៍ថា វិធានការកែទម្រង់ចំនួន ១៦៩ ក្នុងចំណោម ១៧៩ (ស្មើនឹង ៩៤,៤%) ដែលបានដាក់ចេញក្នុងអំឡុងពេលវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ ត្រូវបានអនុវត្តយ៉ាងពេញលេញ ខណៈដែលវិធានការដែលនៅសេសសល់កំពុងមានវឌ្ឍនភាពតាមរយៈការសម្របសម្រួលអន្តរក្រសួង។

ដោយឡែក ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) បានអញ្ជើញ សសក ឱ្យដាក់ជូននូវអនុសាសន៍ផ្សេងៗសម្រាប់វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ លោក អួន ស៊ីឡុត ប្រធាន សសក បានសម្របសម្រួលជាមួយសមាជិកមកពីវិស័យកម្មន្តសាល (ផលិតកម្ម) សហគ្រាសធុនតូច និងមធ្យម (SME) និងវិស័យសេវាកម្មក្នុងសមត្ថកិច្ចរបស់ សសក ដើម្បីស្វែងរកបញ្ហាប្រឈមសំខាន់ៗក្នុងអាជីវកម្ម និងស្នើឡើងនូវដំណោះស្រាយនានា។

អនុសាសន៍ទាំងនោះត្រូវកាលកំណត់ដាក់ជូនក្រសួងឧស្សាហកម្ម ត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ដើម្បីធានាថាអាទិភាពនៃឧស្សាហកម្មស្វាយចន្ទីត្រូវបានរំលេចនៅក្នុងការពិភាក្សាគោលនយោបាយថ្នាក់ជាតិ។

ការនាំចូលទំនិញថែមកកម្ពុជាធ្លាក់ចុះជាង ៣៧% ដែលមានតម្លៃជាង ១,៣ ពាន់លានដុល្លារ នៅក្នុងរយៈពេល ៨ ខែ ឆ្នាំ ២០២៦ ធ្យៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ នេះបើយោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (GDCE) ចេញផ្សាយនៅថ្ងៃទី ១០ កញ្ញា ២០២៦។ KPT Economy

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ប្រទេសអូស្ត្រាលី គាំទ្រការជំរុញរបស់កម្ពុជា ក្នុងការពង្រីកការកែច្នៃស្វាយចន្ទីក្នុងស្រុក

Australia Backs Cambodia's Push to Expand Domestic Cashew Processing



ប្រភព៖ សសក - CAC | តុលា ២០២៥ - Oct 2025 | តំណភ្ជាប់ - Link

ភ្នំពេញ កម្ពុជា ថ្ងៃទី៧ ខែសីហា — ប្រទេសអូស្ត្រាលី បាននិង កំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រីកឧស្សាហកម្មកែច្នៃស្វាយចន្ទីក្នុងស្រុករបស់កម្ពុជា តាមរយៈកិច្ចសហប្រតិបត្តិការដៃគូថ្មីមួយ ដែលត្រូវបានរចនាឡើងដើម្បីលើកកម្ពស់ផលិតកម្មបង្កើតតម្លៃបន្ថែម បង្កើតឱកាសការងារ និងរក្សាតម្លៃសេដ្ឋកិច្ចឱ្យបានកាន់តែច្រើនពីកសិផលសំខាន់របស់ប្រទេស។

ស្ថានទូតអូស្ត្រាលីប្រចាំនៅភ្នំពេញបានឱ្យដឹងថាកម្ពុជាគឺជាប្រទេសផលិតគ្រាប់ស្វាយចន្ទីធំជាងគេទីពីរនៅលើពិភពលោក ប៉ុន្តែកែច្នៃក្នុងស្រុកបានត្រឹមតែប្រមាណ ៥% ប៉ុណ្ណោះនៃផលិតកម្មសរុប។ ការកែច្នៃក្នុងស្រុកមានកម្រិត ត្រូវបានប៉ាន់ប្រមាណថាបានធ្វើឱ្យប្រទេសនេះបាត់បង់ប្រាក់ចំណូលសក្តានុពលជាង ១២៥ លានដុល្លារអាមេរិកជាប្រចាំឆ្នាំ។

ប្រទេសអូស្ត្រាលី កំពុងចាប់ដៃគូជាមួយក្រុមហ៊ុន Olam Food Ingredients (OFI) ដើម្បីពង្រីកសមត្ថភាពកែច្នៃឱ្យបាន៨០តោនក្នុងមួយថ្ងៃ និងកៀរគរទុនវិនិយោគរហូតដល់ ១០ លានដុល្លារអាមេរិក នៅក្នុងវិស័យកែច្នៃស្វាយចន្ទីរបស់កម្ពុជា។

CamNess

PHNOM PENH, Cambodia, Aug. 7 — Australia is supporting efforts to expand Cambodia's domestic cashew processing industry through a new partnership designed to boost value-added production, create jobs and retain more economic value from the country's major agricultural commodity.

The Australian Embassy in Phnom Penh said Cambodia is the world's second-largest producer of raw cashew nuts (RCN), but processes only about 5% of its production domestically. Limited processing is estimated to cost the country more than US$125 million annually in potential revenue.

Australia is partnering with Olam Food Ingredients (OFI) to expand processing capacity by 80 metric tons per day and mobilize up to US$10 million in investment in Cambodia's cashew-processing sector.

The initiative comes as Cambodia continues to export large volumes of RCN, mainly to Vietnam for processing. The Cashew Nut Association of

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

គំនិតផ្តួចផ្តើមនេះ កើតឡើងខណៈដែលកម្ពុជានៅតែបន្តនាំចេញគ្រាប់ស្វាយចន្ទីនៅក្នុងបរិមាណយ៉ាងច្រើន ជាពិសេសទៅកាន់ប្រទេសវៀតណាមសម្រាប់ការកែច្នៃ។ សមាគមស្វាយចន្ទីកម្ពុជា (សសក) បានប៉ាន់ប្រមាណក្រៅផ្លូវការថា កម្ពុជាបាននាំចេញគ្រាប់ស្វាយចន្ទីឆៅ ប្រមាណ ១,០៨ លានតោន ក្នុងអំឡុង៨ខែនៃឆ្នាំ២០២៦ ដោយប្រមូលបានប្រាក់ចំណូលពីការនាំចេញប្រមាណ ១,៨៩ពាន់លានដុល្លារអាមេរិក ដែលជាការកើនឡើង ២៩% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ទិន្នន័យផ្លូវការបានបង្ហាញថា ប្រទេសកម្ពុជាទទួលបានចំណូលចំនួន ៨៨៩ លានដុល្លារអាមេរិកពីការនាំចេញដំឡូងមី ក្នុងរយៈពេលប្រាំបីខែដំបូងនៃឆ្នាំ២០២៦ ដោយសារតែការរើបឡើងវិញនៃតម្លៃទីផ្សារ។

Cambodia (CAC) estimates that Cambodia exported about 1.08 million metric tons of RCN in the first eight months of 2026, generating approximately US$1.89 billion in export earnings, up 29% year on year.

The partnership is expected to support investment, technology transfer and job creation while strengthening domestic value addition and helping Cambodia capture a larger share of the global cashew industry.

កិច្ចសហប្រតិបត្តិការដៃគូនេះ ត្រូវបានរំពឹងថានឹងជួយគាំទ្រដល់ការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា និងការបង្កើតការងារ ខណៈពេលដែលពង្រឹងការបង្កើតតម្លៃបន្ថែមនៅក្នុងស្រុក និងជួយឱ្យកម្ពុជាទាញយកចំណែកកាន់តែធំនៃឧស្សាហកម្មស្វាយចន្ទីសកល។

CAC Contributes to Government-Private Sector Reform Dialogue

Phnom Penh, July 9, 2026 — The Cashew Nut Association of Cambodia (CAC) participated in a high-level workshop on the Royal Government's reform agenda under the Government-Private Sector Forum (G-PSF), highlighting continued collaboration between the public and private sectors to improve Cambodia's business environment.

The workshop, chaired by Deputy Prime Minister H.E. Sun Chanthol, reported that 169 of 179 reform measures (94.4%) introduced during the 19th G-PSF have been fully implemented, with the remaining measures progressing through inter-ministerial coordination.

Separately, the Ministry of Industry, Science, Technology and Innovation (MISTI) invited CAC to submit recommendations for the upcoming Government-Private Sector Forum. CAC President Silot Uon will coordinate with members from the manufacturing, SME and service sectors to identify key business challenges and propose solutions. The recommendations are due to MISTI by July 15, 2026, ensuring the cashew industry's priorities are represented in national policy discussions.

សសក រៀបចំសិក្ខាសាលាបណ្តុះបណ្តាលកសិករនៅខេត្តកំពង់ឆ្នាំង

កំពង់ឆ្នាំង ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៦ — សាខាសមាគមស្វាយចន្ទីកម្ពុជា (សសក) ប្រចាំខេត្តកំពង់ឆ្នាំង បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីបច្ចេកទេសថ្មីៗក្នុងការបង្កើនទិន្នផលស្វាយចន្ទី។ សិក្ខាសាលានេះបានប្រមូលផ្តុំកសិករចំនួន ៣៦ នាក់ (ស្ត្រី ១១នាក់) មកពីខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ កណ្តាល និងរាជធានីភ្នំពេញ។ សិក្ខាកាមបានសិក្សាស្វែងយល់ពីការអនុវត្តការគ្រប់គ្រងដំណាំបែបទំនើប ការប្រើប្រាស់ជី និងថ្នាំកសិកម្មប្រកបដោយប្រសិទ្ធភាព ឧបករណ៍កសិកម្ម ការជំរុញការបែកត្រួយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

អ្នកជំនាញក៏បានណែនាំផងដែរអំពីជីមីក្រុសារពាង្គកាយមានប្រសិទ្ធភាពខ្ពស់ (HEM) និងបច្ចេកទេសលាយថ្នាំគីមីឱ្យបានត្រឹមត្រូវ រួមទាំងសារៈសំខាន់នៃកម្រិត pH របស់ទឹក។ លោក អួន ស៊ីឡុត ប្រធាន សសក បានមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះគឺជាកម្មវិធីដំបូងគេបង្អស់របស់សសក នៅខេត្តកំពង់ឆ្នាំង ដែលជាការពង្រីកការគាំទ្រផ្នែកបច្ចេកទេសឱ្យហួសពីតំបន់ផលិតស្វាយចន្ទីសំខាន់ៗ ព្រមទាំងជួយកសិករកាត់បន្ថយការចំណាយ បង្កើនទិន្នផល និងសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

គណៈប្រតិភូធុរកិច្ចកម្ពុជាស្វែងរកការពង្រីកទំនាក់ទំនងពាណិជ្ជកម្មជាមួយអឺរ៉ុប

Cambodian Business Delegation Explores European Trade and Investment Opportunities

ប្រភព៖ សសក | កញ្ញា ២០២៦ - September 2026 | តំណភ្ជាប់ - Link

គណៈប្រតិភូធុរកិច្ចកម្ពុជា ដឹកនាំដោយក្រុមហ៊ុន Pinex Agro Co., Ltd. បានបញ្ចប់បេសកកម្មពាណិជ្ជកម្មទៅកាន់ប្រទេសឡាតវី រូម៉ានី និងប៊ុលហ្គារី ក្នុងគោលបំណងពង្រីកទំនាក់ទំនងពាណិជ្ជកម្ម និងការវិនិយោគរវាងកម្ពុជា ជាមួយទីផ្សារអឺរ៉ុប។ បេសកកម្មនេះបានវាយតម្លៃលើឱកាសធុរកិច្ច និងការវិនិយោគ តម្រូវការទីផ្សារ ស្តង់ដារភស្តុភារកម្ម និងការវេចខ្ចប់របស់សហភាពអឺរ៉ុប ព្រមទាំងស្វែងរកការតភ្ជាប់ទំនាក់ទំនងដោយផ្ទាល់រវាងធុរកិច្ចកម្ពុជា ជាមួយអ្នកទិញ និងវិនិយោគិនអឺរ៉ុប។ នៅរដ្ឋធានីសូហ្វៀ គណៈប្រតិភូបានរៀបចំកិច្ចប្រជុំធុរកិច្ចជាមួយក្រុមហ៊ុន M3 Group ដែលត្រូវបានសម្របសម្រួលដោយឯកឧត្តម បណ្ឌិត ជា ចាន់បរិបូណ៌ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសប៊ុលហ្គារី ដោយមានការចូលរួមពីតំណាងធុរកិច្ច និងអ្នកជំនាញពាណិជ្ជកម្មកម្ពុជា និងប៊ុលហ្គារី។ កាលពីពេលមុននេះ នៅថ្ងៃទី១៥ ខែកញ្ញា មន្ត្រីកម្ពុជា និងតំណាងវិស័យឯកជន បានជួបប្រជុំជាមួយសភាពាណិជ្ជកម្ម និងឧស្សាហកម្មរូម៉ានី ព្រមទាំងសភាពាណិជ្ជកម្ម និងឧស្សាហកម្មរដ្ឋធានីប៊ុយការេស។ កិច្ចពិភាក្សាទាំងនោះបានប្រមូលផ្តុំធុរកិច្ចមកពីវិស័យកែច្នៃកសិផល ភស្តុភារកម្ម និងបច្ចេកវិទ្យាឌីជីថល។ លោកស្រី ពិន ភិរម្យ អគ្គនាយិកាក្រុមហ៊ុន UNI Holding និងជានាយិកាប្រតិបត្តិនៃក្រុមហ៊ុន Pinex Agro បានមានប្រសាសន៍ថា ការជួបប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអ្នកទិញ និងវិនិយោគិនអឺរ៉ុប អាចជួយឱ្យអ្នកផលិតកម្ពុជាទទួលបានតម្លៃកាន់តែប្រសើរ និងពង្រីកលទ្ធភាពចូលទៅកាន់ទីផ្សារបានកាន់តែទូលំទូលាយ។

A Cambodian business delegation led by Pinex Agro Co., Ltd. has concluded a trade mission to Latvia, Romania and Bulgaria aimed at expanding trade and investment ties between Cambodia and European markets.

The mission assessed business and investment opportunities, market demand, EU logistics and packaging standards, while seeking direct links between Cambodian businesses and European buyers and investors.

In Sofia, the delegation held a business session with M3 Group, coordinated by Cambodian Ambassador to Bulgaria H.E. Dr. Chea Chanboribo, with participation from Cambodian and Bulgarian business representatives and trade experts.

Earlier, on September 15, Cambodian officials and private-sector representatives held meetings with Romania's Chamber of Commerce and Industry and the Bucharest Chamber of Commerce and Industry. Discussions brought together businesses from agricultural processing, logistics and digital technology.

Ms. Pin Phirom, Director General of UNI Holding and Executive Director of Pinex Agro, said direct engagement with European buyers and investors could help Cambodian producers secure better prices and broaden market access.

Cambodia earned US$489 million from cassava exports in the first eight months of 2026, official data showed Tuesday, as recovering market prices and a shift toward higher-value dried products sustained the sector despite a sharp drop in

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

កសិករដាំស្វាយចន្ទីខេត្តក្រចេះ ត្រៀមសម្រួបខ្លួនទប់ផលប៉ះពាល់ដែលអាចកើតមានពីបាតុភូត Super El Nino

ក្រចេះ កម្ពុជា ថ្ងៃទី១៦ ខែសីហា — សាខាសមាគមស្វាយចន្ទីកម្ពុជា (សសក) សាខាខេត្តក្រចេះ បានរៀបចំកិច្ចពិភាក្សា និងចុះសិក្សាឈ្វេងយល់ជាក់ស្តែងនៅតាមចម្ការ ដើម្បីជួយដល់កសិករដាំស្វាយចន្ទីក្នុងការត្រៀមខ្លួនទប់ទល់នឹងផលប៉ះពាល់អាកាសធាតុដែលអាចកើតមានពីបាតុភូត Super El Niño ដែលជិតមកដល់ ដោយមានការចូលរួមពីសិក្ខាកាមចំនួន ៩៥ នាក់ មកពីខេត្តក្បែរខាងចំនួនបួន។

ព្រឹត្តិការណ៍នេះបានផ្តោតលើវិធានការគ្រប់គ្រងចម្ការជាក់ស្តែង ដើម្បីរក្សាផលិតភាពស្វាយចន្ទីចំពេលមានការប្រែប្រួលលក្ខខណ្ឌអាកាសធាតុ រួមមាន៖ ការអនុវត្តការងារក្នុងចម្ការឱ្យបានទាន់ពេលវេលា ការគ្រប់គ្រងសមាសភាពចង្រៃ និងជំងឺ ការផ្តល់សារធាតុចិញ្ចឹមបានត្រឹមត្រូវ និងការគិតគូរពីលក្ខខណ្ឌដីព្រមទាំងបរិស្ថាន។

កសិករត្រូវបានណែនាំឱ្យត្រៀមខ្លួនទប់ទល់នឹងការបែកត្រួយលឿនខុសប្រក្រតី ការកើនឡើងនៃសកម្មភាពសត្វល្អិតចង្រៃ ការប្រែប្រួលនៃសម្ពាធជំងឺ និងការដណ្តើមសារធាតុចិញ្ចឹមកាន់តែខ្លាំងពីសំណាក់ស្មៅចង្រៃ។ សិក្ខាកាមក៏ត្រូវបានលើកទឹកចិត្តឱ្យតាមដានដើមចន្ទីរបស់ខ្លួនឱ្យបានទៀងទាត់ និងចុះត្រួតពិនិត្យចម្ការនៅពេលវេលាសមស្រប ជាពិសេសនៅមុនម៉ោង ៩ ព្រឹក។

កិច្ចពិភាក្សាបានគូសបញ្ជាក់ពីសារៈសំខាន់នៃការកំណត់ពេលវេលាឱ្យបានច្បាស់លាស់ក្នុងការប្រើប្រាស់ថ្នាំកសិកម្ម និងធាតុចូលកសិកម្ម។ កសិករត្រូវបានណែនាំឱ្យជៀសវាងការបាញ់ថ្នាំនៅចន្លោះពីម៉ោង ១២ ថ្ងៃត្រង់ ដល់ម៉ោង ៣ រសៀល ដែលជាពេលសីតុណ្ហភាពឡើងខ្ពស់អាចកាត់បន្ថយប្រសិទ្ធភាពថ្នាំ និងត្រូវគិតគូរពីសំណើមខ្យល់ព្រមទាំងសំណើមដីនៅពេលថែទាំដំណាំ។



Credit Picture: Royal Embassy of Cambodia to the Republic of Bulgaria.

Kratie Cashew Farmers Prepare for Potential Super El Niño Impacts

KRATIE, Cambodia, Aug. 16 — The Kratie Provincial Branch of the Cashew Nut Association of Cambodia (CAC) held a discussion and field study to help cashew farmers prepare for potential climate impacts associated with an approaching Super El Niño, bringing together 95 participants from four neighboring provinces.

The event focused on practical farm-management measures to maintain cashew productivity amid changing weather conditions, including timely farm operations, pest and disease management, proper nutrient application and consideration of soil and environmental conditions.

Farmers were advised to prepare for potential rapid shoot growth, increased pest activity, changes in disease pressure and greater competition from weeds for nutrients. Participants were also encouraged to regularly monitor their trees and conduct field

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ទន្ទឹមនឹងនេះ សិក្ខាកាមក៏បានពិភាក្សាអំពីហានិភ័យនៃការប្រើប្រាស់សារធាតុគីមីកសិកម្មហួសកម្រិត ឬមិនត្រឹមត្រូវតាមបច្ចេកទេស ដែលអាចបណ្តាលឱ្យសត្វល្អិតស៊ាំនឹងថ្នាំ និងធ្វើឱ្យការគ្រប់គ្រងសត្វល្អិតចង្រៃនាពេលអនាគតកាន់តែពិបាក។

សសក បានឱ្យដឹងថា សាខាទាំង ១១ រាជធានី-ខេត្តរបស់ខ្លួន នៅតែបន្តអនុវត្តសកម្មភាពចុះផ្ទាល់ដល់មូលដ្ឋាន ក្នុងគោលបំណងពង្រឹងវិស័យស្វាយចន្ទីរបស់សមាជិក និងគាំទ្រដល់ភាពធន់យូរអង្វែងរបស់កសិករ។



ជំនួបធុរកិច្ច របស់ សសក បង្កើតបានតម្រូវការគ្រាប់ស្វាយចន្ទីរៅ ឈានដល់ ១៤៤ ០០០ តោន

កំពង់ធំ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៦ — សមាគមស្វាយចន្ទីកម្ពុជា (សសក) បានតភ្ជាប់កសិករដាំស្វាយចន្ទី និងសហគមន៍កសិកម្ម ជាមួយរោងចក្រកែច្នៃ និងពាណិជ្ជករ តាមរយៈជំនួបធុរកិច្ច (B2B) ក្នុងគោលបំណងពង្រឹងការតភ្ជាប់ទីផ្សារនិងពង្រីកលទ្ធភាពទទួលបានដៃគូទិញ។

ព្រឹត្តិការណ៍នេះបានប្រមូលផ្តុំអ្នកចូលរួមប្រមាណ ៤០ នាក់ (ស្រី១៨នាក់) រួមមានអ្នកទិញគ្រាប់

inspections at appropriate times, particularly before 9 a.m.

The discussion highlighted the importance of carefully timing pesticide and agricultural-input applications. Farmers were advised to avoid spraying between noon and 3 p.m., when high temperatures can reduce effectiveness, and to consider air humidity and soil moisture when managing crops.

Participants also discussed the risks of excessive or inappropriate use of agricultural chemicals, which can contribute to pest resistance and make future pest management more difficult.

The CAC said its 11 provincial and municipal branches continue to implement field activities aimed at strengthening the country's cashew sector and supporting farmers' long-term resilience.

The association emphasized that improving the sector requires continued cooperation among farmers, private-sector stakeholders and industry organizations, particularly as climate variability creates new challenges for cashew production.

CAC B2B Dialogue Generates 144,000-Tonne RCN Demand

KAMPONG THOM, Sept. 10, 2026 — The Cashew Nut Association of Cambodia (CAC) has connected cashew farmers and agricultural cooperatives with processors and traders through a business-to-business (B2B) dialogue aimed at strengthening market linkages and expanding access to buyers.

The event brought together about **40 participants**, including RCN buyers, large-scale farmers, five agricultural cooperatives and three financial institutions. Participating companies expressed potential demand for a combined **144,000 metric tonnes of RCN**, led by Royal Delight View of India with 50,000 tonnes, Olam Outspan and a Chinese processor with 30,000 tonnes each, and Khmer Agro Cashew with 15,000 tonnes.

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ស្វាយចន្ទីឆៅ កសិករខ្នាតធំ សហគមន៍កសិកម្ម ចំនួន៥ និងគ្រឹះស្ថានហិរញ្ញវត្ថុចំនួន៣។ ក្រុមហ៊ុន ដែលបានចូលរួមបានបង្ហាញពីតម្រូវការសក្តានុពល សរុបចំនួន ១៥៥ ០០០ តោននៃគ្រាប់ស្វាយចន្ទីឆៅ ដែលនាំមុខដោយក្រុមហ៊ុន Royal Delight View មក ពីប្រទេសឥណ្ឌាចំនួន ៥០ ០០០ តោន ក្រុមហ៊ុន Olam និងក្រុមហ៊ុនកែច្នៃរបស់ចិនមួយចំនួន ៣០ ០០០ តោនក្នុងមួយក្រុមហ៊ុន និងក្រុមហ៊ុន Khmer Agro Cashew ចំនួន ១៥ ០០០ តោន។

ក្រុមហ៊ុន Mertol Sunflower Import & Export និង ក្រុមហ៊ុន Special Trust Cambodia ក៏បានបង្ហាញពី ចំណាប់អារម្មណ៍ក្នុងការទិញគ្រាប់ស្វាយចន្ទីកែច្នៃ រួច ផងដែរ។

ការពិភាក្សាបានផ្តោតលើស្តង់ដារគុណភាពគ្រាប់ ស្វាយចន្ទីឆៅ កសិកម្មកិច្ចសន្យា វិធីសាស្ត្រទូទាត់ ប្រាក់ និងសមត្ថភាពរបស់សហគមន៍ក្នុងការផ្គត់ផ្គង់ បរិមាណធំ។ កសិករដែលបំពេញតាមលក្ខខណ្ឌ គុណភាពល្អ អាចនឹងទទួលបានការលើកទឹកចិត្ត បន្ថែមលើតម្លៃ ៣%។

អ្នកចូលរួមក៏បានអំពាវនាវឱ្យមានការពង្រឹងការត្រួត ពិនិត្យគុណភាពនៅឯកសិដ្ឋានផ្ទាល់ និងលក្ខខណ្ឌ ពាណិជ្ជកម្មឱ្យកាន់តែច្បាស់លាស់ រួមទាំងលក្ខខណ្ឌ EXW និង FOB ផងដែរ។ ជាមួយគ្នានេះ ធនាគារ កាណាឌីយ៉ា ធនាគារចិន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ (AMK) បានពិភាក្សាអំពីសេវាហិរញ្ញ ប្បទាន និងសេវាទូទាត់ប្រាក់។

សមាគមស្វាយចន្ទីកម្ពុជា បានបញ្ជាក់ថា ជំនួបធុរ កិច្ចលើកក្រោយដែលគ្រោងធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ ២០២៦ នឹងផ្តោតលើគុណភាពពូជ M23 និងការចាត់ ថ្នាក់ទំហំតូចជាងមុនប្រភេទ W320។



Mertol Sunflower Import & Export and Special Trust Cambodia also expressed interest in purchasing cashew kernels.

Discussions focused on RCN quality standards, contract farming, payment methods and cooperatives' capacity to supply large volumes. Farmers meeting premium quality requirements could receive a **3% price incentive**.

Participants also called for stronger farm-gate quality control and clearer trading terms, including **EXW and FOB**. Canadia Bank, Bank of China and AMK Microfinance discussed financing and payment services.

CAC said the next B2B dialogue, planned for November, will focus on M23 quality and smaller W320 classifications.



ទិន្នន័យក្រៅផ្លូវការខែសីហានេះ កម្ពុជានាំគ្រាប់ចន្ទីឆៅចេញក្រៅប្រទេស ១ ០៨០ ០០០ តោន គិតជាទឹកប្រាក់ ១ ៨៩០ លានដុល្លា (កើនឡើង ២៩%)

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

2. ព័ត៌មានអន្តរជាតិ - International News



★★★ ព័ត៌មានសំខាន់ៗ - News Highlights

អាហ្វ្រិក ពង្រីកការកែច្នៃស្វាយចន្ទី ដើម្បីចាប់យកតម្លៃបន្ថែមឱ្យបានកាន់តែច្រើន

កំពង់ធំ ខែកក្កដា ឆ្នាំ២០២៦ — បណ្តាប្រទេសនៅទ្វីបអាហ្វ្រិក កំពុងពន្លឿនការវិនិយោគលើការកែច្នៃស្វាយចន្ទីក្នុងស្រុកខណៈដែលបណ្តាប្រទេសផលិតគ្រាប់ឆៅស្វែង ចាប់យកតម្លៃបន្ថែមឱ្យបានកាន់តែច្រើនពីកសិផល ដែលគ្របដណ្តប់លើសពី ៦០% នៃផលិតកម្មគ្រាប់ស្វាយចន្ទី សរុបនៅលើពិភពលោក។ ប្រទេសផលិតឈានមុខគេ រួមមាន ប្រទេសកូដឌីវ័រ (Ivory Coast) បេណាំង (Benin) ហ្គាណា (Ghana) តង់ហ្សានី (Tanzania) គីនេប៊ីស្សូ (Guinea-Bissau) និងម៉ូសំប៊ិក (Mozambique) បាននិងកំពុងពង្រីកសមត្ថភាពកែច្នៃរបស់ខ្លួន ដើម្បីជំរុញការនាំចេញ បង្កើតឱកាសការងារ និងពង្រឹងឧស្សាហកម្មក្នុងស្រុក។

ទោះបីជាមានវឌ្ឍនភាពយ៉ាងណាក៏ដោយ លក្ខខណ្ឌទីផ្សារនៅតែបន្តស្ថិតក្នុងស្ថានភាពប្រុងប្រយ័ត្ន។ ប្រទេសកូដឌីវ័រ បានកាត់បន្ថយតម្លៃទិញនៅចម្ការផ្លូវ

Africa Expands Cashew Processing to Capture More Value

Kampong Thom, July 2026 — Africa is accelerating investment in domestic cashew processing as producing countries seek to capture more value from a crop that accounts for over 60% of global raw cashew nut (RCN) production. Leading producers, including Côte d'Ivoire, Benin, Ghana, Tanzania, Guinea-Bissau and Mozambique, are expanding processing capacity to boost exports, create jobs and strengthen local industries.

Despite the progress, market conditions remain cautious. Côte d'Ivoire reduced its 2026 farmgate price for raw cashew nuts by 6% while Ghana lowered producer prices by about 20%, reflecting softer global prices, a weaker U.S. dollar and changing trade conditions.

Industry analysts say expanding local processing remains Africa's best strategy for increasing export earnings and building globally competitive cashew

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ការសម្រាប់គ្រាប់ស្វាយចន្ទីឆៅ ក្នុងឆ្នាំ២០២៦ ចំនួន ៦% ខណៈដែលប្រទេសហ្គាណាបានទម្លាក់តម្លៃទិញពីផលិតករប្រមាណ ២០% ដែលការទម្លាក់តម្លៃនេះឆ្លុះបញ្ចាំងពីការចុះខ្សោយនៃតម្លៃនៅលើទីផ្សារសកល ការធ្លាក់ចុះនៃតម្លៃប្រាក់ដុល្លារអាមេរិក និងការប្រែប្រួលនៃលក្ខខណ្ឌពាណិជ្ជកម្ម។

ក្រុមអ្នកវិភាគឧស្សាហកម្មបានលើកឡើងថា ការពង្រីកការកែច្នៃក្នុងស្រុក នៅតែជាយុទ្ធសាស្ត្រល្អបំផុតរបស់អាហ្វ្រិកក្នុងការបង្កើនប្រាក់ចំណូលពីការនាំចេញ និងការកសាងម៉ាកយីហោស្វាយចន្ទីដែលមានភាពប្រកួតប្រជែងខ្ពស់នៅលើឆាកអន្តរជាតិ ដោយប្រទេសកូដឌីវ័រ កំពុងត្រូវបានគេមើលឃើញកាន់តែខ្លាំងឡើងថាជាគំរូសម្រាប់ការអភិវឌ្ឍឧស្សាហកម្មបង្កើតតម្លៃបន្ថែម។

brands, with Côte d'Ivoire increasingly viewed as a model for value-added industrial development.



CAC Completes Three-Day Training to Strengthen its Members' Cashew Processing Sector

KAMPONG THOM, Cambodia, Aug. 7, 2026 — The Cashew Nut Association of Cambodia (CAC) has completed a three-day practical training program aimed at strengthening technical skills and expanding domestic cashew processing capacity.

Held from Aug. 5 to 7 at the CAC head office in Kampong Thom province, the Cashew Nut Processing Training Program addressed technical and resource gaps limiting the competitiveness and profitability of Cambodia's growing cashew-processing industry.

The training covered post-harvest management, processing techniques, quality control, machinery operation, financial management and value addition. Sessions were developed based on consultations with existing and prospective processors and a training needs assessment.

Qualified staff from Mirath, Pinex and Nuts & Nest Enterprise facilitated the program, with practical sessions held at Nuts & Nest Enterprise. Participants received hands-on training in steaming, shelling, roasting and peeling cashew nuts.

The program also introduced international kernel grading standards, food safety, storage, moisture management, processing technologies and machinery selection. Participants learned to assess production costs, revenues, profit margins, break-even points and financial risks.

The training further highlighted opportunities to generate additional income from cashew-processing by-products, including cashew nut shell liquid (CNSL), cashew nut shell extract (CNSE) and agricultural waste for biochar production.

CAC said greater use of by-products could reduce waste, create new revenue streams and improve industry sustainability.

The initiative supports broader efforts to increase domestic processing, retain more value from Cambodia's cashew production, create jobs and improve incomes for farmers and businesses.

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃការកែច្នៃស្វាយចន្ទីរបស់ប្រទេសកូដឌីវ័រ



ប្រភព៖ សសក - CAC | កក្កដា ២០២៦ - July 2026 | តំណភ្ជាប់ - Link

កំពង់ធំ ខែកក្កដា ឆ្នាំ២០២៦ — ប្រទេសកូដឌីវ័រ (Côte d'Ivoire) បាននិងកំពុងពង្រឹងទីតាំងរបស់ខ្លួនជាមជ្ឈមណ្ឌលកែច្នៃស្វាយចន្ទីសកល ដោយបាននាំចេញសាច់គ្រាប់ស្វាយចន្ទីចំនួន ៤៤ ៤០៣ តោន ក្នុងអំឡុងពេលប្រាំខែដំបូងនៃឆ្នាំ២០២៦ ដែលកើនឡើង ៥១% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន យោងតាមទិន្នន័យពី N'kalô។ គោលនយោបាយរបស់រដ្ឋាភិបាលដែលផ្តល់អាទិភាពលើការកែច្នៃក្នុងស្រុក អមដោយការផ្តល់ប្រាក់ឧបត្ថម្ភធន និងការលើកទឹកចិត្តផ្នែកពន្ធ បានបង្កើនអត្រានៃការកែច្នៃរបស់ប្រទេសនេះដល់ ៤៣% បើប្រៀបធៀបទៅនឹងឆ្នាំ ២០២៤ គឺត្រឹមតែ ៦,២% ប៉ុណ្ណោះ។

ទោះបីជាមានវឌ្ឍនភាពយ៉ាងណាក៏ដោយ សាច់គ្រាប់ស្វាយចន្ទីកែច្នៃបឋមភាគច្រើនរបស់ប្រទេសកូដឌីវ័រ នៅតែត្រូវបានដឹកជញ្ជូនទៅកាន់ប្រទេសវៀតណាម សម្រាប់ការកែច្នៃចុងក្រោយ និងការនាំចេញបន្ត។

លោក **អួន ស៊ីឡុត** ប្រធានសមាគមស្វាយចន្ទីកម្ពុជា បានមានប្រសាសន៍ថា ជោគជ័យរបស់ប្រទេសកូដឌីវ័រ បង្ហាញឱ្យឃើញពីរបៀបដែលការវិនិយោគជាយុទ្ធសាស្ត្រ និងគោលនយោបាយគាំទ្រ អាចប្រែក្លាយកសិផលវត្ថុធាតុដើម ឱ្យទៅជាឧស្សាហកម្មនាំចេញដែលមាន

Côte d'Ivoire's Cashew Processing Boom Offers Lessons for Cambodia

Kampong Thom, July 2026 — Côte d'Ivoire is strengthening its position as a global cashew processing hub, exporting 44,403 metric tons of cashew kernels in the first five months of 2026, up 51% year-on-year, according to N'kalô data. Government policies prioritizing domestic processing, along with subsidies and tax incentives, have increased the country's processing rate to 43%, compared with just 6.2% in 2014.

Despite the progress, much of Côte d'Ivoire's semi-processed kernels are still shipped to Vietnam for final processing and re-export.

Silot Uon, Chairman of the Cashew Nut Association of Cambodia (CAC), said Côte d'Ivoire's success demonstrates how strategic investment and supportive policies can transform a raw commodity into a high-value export industry. He noted that Cambodia, the world's second-largest producer of raw cashew nuts, could generate more jobs and higher export earnings by expanding domestic processing and value addition.

National Road 06, Sangkat Acharleak, Krong Stung Sen, Kampong Thom Province
+855 77 629 288/+855 31 5555 706, info@cac-camcashew.org
https://cac-camcashew.org/

